# គោលការណ៍ក្នុងការអប់រំកូន

ដោយ ក្រោលី ចេឌី និង ឃីម



## មេរៀនទី១

# គោលការណ៍ក្នុងការអប់រំកូន

## ក. អ្នកត្រូវដឹងថា កូនរបស់អ្នកជាកម្មសិទ្ធរបស់ផងព្រះ

ព្រះជាម្ចាស់បានប្រទានអោយអ្នកចិញ្ចឹមបីបាច់ថែរក្សាក្នុងរយៈពេលខ្លី ។ ទ្រង់បានប្រទានកូន អោយអ្នក ដើម្បីសិរីរុងរឿងរបស់ទ្រង់ មិនមែនគ្រាន់តែជារបស់សំរាប់អ្នកប្រើនោះទេ។ គម្ពីរទំនុកដំកើង ១២៧:៣-៥ ឧទាហរណ៍: បើសិនជាសម្តេចហ៊ុនសែនបានប្រគល់ កូនរបស់ផងគាត់មួយអោយទៅអ្នកចិញ្ចឹមថែរក្សា តើអ្នកនឹងយកចិត្តទុកដាក់យ៉ាងណា ក្នុងការចិញ្ចឹមថែរក្សាកូននោះ? ចុះចំណែកឯកូនរបស់ព្រះដែលទ្រង់ប្រទានអោយយើងចិញ្ចឹមថែរក្សា នោះរឹតតែវិសេសវិសាលជាងអ្វីទៅទៀត។

អ្នកត្រូវដឹងថាកូនរបស់យើងម្នាក់ៗ មានទាំងរូបកាយ គំនិត និងចិត្ត ។ ជាធម្មតានៅស្រុកខ្មែរ យើងជាឪពុកម្តាយតែងតែយកចិត្តទុកដាក់ចំពោះរូបកាយ និង គំនិតចេះដឹងរបស់កូនយើង។ យើងច្រើនតែគិតទៅលើសំលៀកបំពាក់ ម្ហូបអាហារដែលមានជីវជាតិ និង ការរៀនសូត្រ។ យើងសុខចិត្តចំណាយប្រាក់ អោយកូនទៅរៀនគួរ ទៅរៀនអង់គ្លេស ហើយទៅរៀនកំព្យូទរ័ ។ នេះជាការល្អហើយ ប៉ុន្តែបន្ថែមពីលើនេះទៅទៀត យើងដែលជាឪពុកម្តាយគ្រីស្ទាន ត្រូវយកចិត្តទុកដាក់ចំពោះចិត្តរបស់កូនយើង។ កូនយើងជាកម្មសិទ្ធិរបស់ព្រះអង្គ ។ ចំពោះព្រះអង្គ ចិត្តរបស់មនុស្សសំខាន់ជាងអ្វីៗទាំងអស់ យើងត្រូវចិញ្ចឹមថែរក្សា និងការពារចិត្តរបស់កូនយើងជាជាងរូបកាយ និងគំនិត។

## ខ. មានតែឪពុកម្តាយប៉ុណ្ណោះដែលបានទទួលភារកិច្ចពីព្រះជាម្ចាស់ដើម្បីអប់រំកូន។

ក្រៅពីឪពុកម្តាយ មនុស្សឯទៀតគ្រាន់តែជាចំណែកក្នុងការជួយប៉ុណ្ណោះ ដូចជាៈ គ្រូគង្វាល គ្រូកុមារ គ្រូយុវជន គ្រូបង្រៀន និងបងប្អូន ។ល។ ប៉ុន្តែ ឪពុកម្តាយមិនអាចផ្ទេរភារកិច្ចនេះ ទៅអ្នកដទៃឡើយ។ ដូច្នេះចូរអោយឪពុកម្តាយប្រយ័ត្នពីអ្នកណាជាអ្នកថែរក្សា និងបង្រៀនកូនរបស់យើង។ បើសិនជាកូនអ្នកខូច អ្នកជាឪពុកម្តាយមិនអាចដោះសារខ្លួន ដោយបន្ទោសក្រុមជុំនំ សាលារៀន ទូរទស្សន៍ សង្គម ឬ អ្នកមើលកូនបានឡើយ ។ បើអ្នករវល់ខ្លាំងពេកមិនអាចថែរក្សាកូនរបស់អ្នកបាន កុំយក។ សូមអាន អេភេសូរ ៦:៨

ឧទាហរណ៍ៈ នៅក្នុងគម្ពីរសញ្ញាចាស់ ស្តេចល្អៗ តែងតែមានកូនអាក្រក់ក្រៃលែង។ ប្រហែលជាគេរវល់ខ្លាំងពេក បានជាគេប្រគល់កូនទៅអោយមេដោះ ជាអ្នកថែរក្សា។ កូនស្តេចដាវីឌភាគច្រើនជាមនុស្សអាក្រក់។ កូនស្តេចសាឡូម៉ូន ឈ្មោះ រេហូបោម ជាស្តេចល្ងង់។ យ៉ូសៀសដែលជាស្តេចអ៊ីស្រាអែលល្អជាងគេ មានកូនម្នាក់ឈ្មោះយ៉ូអាហាស ដែលត្រូវស្តេចផារ៉ោនចាប់ដាក់ខ្នោះ ព្រោះគាត់អាក្រក់។ អេលី និង សាំយ៉ូអែល ក៏មានកូនដែលធ្វើអោយបង្អាប់ព្រះនាមរបស់ព្រះអង្គដែរ។ យើងគិតថា ឪពុកទាំងអស់នេះ គ្មានពេលអប់រំ និងប្រៀនប្រដៅកូន។ សព្វថ្ងៃនេះ ឪពុកម្តាយជាច្រើនក៏គ្មានពេលសំរាប់មើល និងអប់រំកូនដែរ គេបានផ្ញើរកូន នឹងសាលា ផ្ញើរនឹងយាយ ឬ ផ្ញើរនឹងអ្នកមើលក្មេង។ តែគេមិនអាចគេចវេសពីតួនាទីនេះបានទេ។

## គ. គោលបំណងក្នុងការអប់រំកូនយើង គឺដើម្បីអោយព្រះអង្គទទួលសិរីរុងរឿង តាមរយៈជីវិតរបស់គេ។

មានន័យថាកូនរបស់យើងនឹង ស្គាល់ព្រះ ស្រឡាញ់ព្រះ ស្តាប់បង្គាប់ព្រះ និងបំរើព្រះ។ (យើងនឹងបង្រៀនពីការទាំង៤នេះនៅមេរៀនក្រោយ)

## ឃ. កូនរបស់អ្នករាល់គ្នាកើតមកមានចិត្តអាក្រក់ ដែលទាស់នឹងព្រះហឫទ័យព្រះ បើមិនផ្លាស់ប្តូរទេ ចិត្តគេនឹងនាំឲ្យគេស្លាប់ ហើយទៅស្ថាននរកអស់កល្បជានិច្ច។

សុភាសិត ៩:២៣, ទំនុកតំកើង ៥១:៥, ៥៨:៣

ហេតុអ្វីបានជាកូនរបស់អ្នកមិនស្តាប់បង្គាប់អ្នក? តើមកពីគេនៅតូចមិនទាន់ដឹងក្តីឬ? ទេ! គេមិនស្តាប់បង្គាប់អ្នក ពីព្រោះគេកើតមកដោយមានចិត្តអាក្រក់ស្រាប់។ បើព្រះអង្គផ្លាស់ប្តូរចិត្តរបស់គេ នោះសេចក្តីប្រព្រឹត្តរបស់គេនឹងផ្លាស់ប្តូរដែរ តែបើអ្នកគ្រាន់តែបង្ខំកូនឲ្យផ្លាស់ប្តូរការប្រព្រឹត្តខាងក្រៅតែប៉ុណ្ណោះ តែមិនសួរគិតពីចិត្តរបស់គេ នោះនឹងធ្វើឲ្យកូនអ្នកកាន់តែអាក្រក់ឡើង ដូច្នេះចូរអធិស្ឋានអោយកូន ដោយឥតឈប់ឈរ។

មេរៀនទី២

# ឪពុកម្តាយត្រូវបង្រៀនកូនអោយស្គាល់ ស្រលាញ់ ស្តាប់បង្គាប់ បំរើ និងជឿ ព្រះជាម្ចាស់

## ក. ឪពុកម្តាយត្រូវបង្រៀនកូនអោយស្គាល់ព្រះជាម្ចាស់

ឪពុកម្តាយត្រូវទទួលភារកិច្ចនាំកូនអោយស្គាល់ព្រះអង្គ។ កុំពឹងលើក្រុមជំនុំដើម្បីបំពេញ ភារកិច្ចនេះ ក្នុងមួយអាទិត្យក្រុមជុំនំជួបជុំគ្នាបានតែបីម៉ោងប៉ុណ្ណោះ ដូច្នេះមិនគ្រប់គ្រាន់ នឹងនាំកូនអោយស្គាល់ព្រះអង្គច្បាស់ទេ។

**មានកិច្ចការ៦យ៉ាង**ដែលឪពុកម្តាយត្រូវធ្វើ ដើម្បីនាំកូនអោយស្គាល់ព្រះអង្គ

១. ឪពុកម្តាយត្រូវអោយកូនឃើញថា ឪពុកម្តាយស្គាល់ព្រះអង្គ ហើយចូលចិត្តចំណាយពេលជាមួយទ្រង់ ។

២. ឪពុកម្តាយត្រូវនិយាយអំពីព្រះគ្រប់ពេល និងគ្រប់កាលៈទេសៈ អាន ចោទិយកថា ៦:៤-៩ អ្នកតែងតែនិយាយអំពីអ្វីៗដែលសំខាន់ចំពោះខ្លួនអ្នក បើសិនជាព្រះសំខាន់ជាងគេ ក្នុងជីវិតអ្នក អ្នកនឹងនិយាយអំពីព្រះអង្គជានិច្ច ។ កូនរបស់អ្នកនឹងឃើញថា ឪពុកម្តាយស្គាល់ព្រះអង្គជិតស្និទ្ធណាស់។ គេនឹងមានគំនិតថា ឪពុកម្តាយខ្ញុំស្គាល់ ព្រះជាម្ចាស់ច្បាស់ណាស់ ខ្ញុំចង់ស្គាល់ព្រះអង្គដូចឪពុកម្តាយខ្ញុំដែរ។ ឪពុកម្តាយត្រូវឆ្លៀតពេលនិយាយអំពីព្រះអង្គជាមួយកូន ដូចជា: ពេលញ៉ាំបាយ ពេលដើរជាមួយគ្នា ពេលធ្វើការជាមួយគ្នា និងពេលជិះម៉ូតូជាមួយគ្នា ។

៣. ឪពុកម្តាយត្រូវអានរឿងនៅក្នុងព្រះគម្ពីរអោយកូនស្តាប់ ហើយសួរគេថា តើរឿងដែលយើងអានអម្បាញ់មិញ បង្រៀនយើងយ៉ាងម៉េចខ្លះអំពីព្រះជាម្ចាស់? (អ្នកអាចប្រើគម្ពីរកុមារដែលមានរូបភាពច្រើន ហើយស្អាតៗ ឬសៀវភៅគ្រីះមាំ) ។

៤. ឪពុកម្តាយត្រូវទន្ទេញខគម្ពីរជាមួយកូន ជាពិសេសខគម្ពីរដែលបញ្ជាក់ពីលក្ខណៈរបស់ព្រះអង្គ។ កុំអោយគិតថា កូនតូចអាយុប្រាំឆ្នាំក្មេងពេក មិនអាចទន្ទេញខគម្ពីរបាន ។

៥. ឪពុកម្តាយត្រូវអធិស្ឋានជាមួយកូនរាល់ថ្ងៃ ។

៦. ឪពុកម្តាយត្រូវអធិស្ឋានសំរាប់កូនរាល់ថ្ងៃ ។

ចូរប្រយ័ត្ន! សត្រូវធំមួយរបស់ក្រុមគ្រួសារគ្រីស្ទាន គឺទូរទស្សន៍ វាស៊ីពេលវេលាដែលយើង គួរចំណាយក្នុងការពិភាក្សាជាមួយកូន ហើយវានាំសេចក្តីអាក្រក់គ្រប់យ៉ាង ចូលមកក្នុងគ្រួសារយើង ។

## ខ. ឪពុកម្តាយត្រូវបង្រៀនកូនអោយស្រលាញ់ព្រះជាម្ចាស់

១. ដើម្បីស្រលាញ់ព្រះអង្គ កូនរបស់អ្នកត្រូវកើតជាថ្មី ដូច្នេះចូរអធិស្ឋានរាល់ថ្ងៃដើម្បីសុំអោយ ព្រះអង្គសង្គ្រោះគេ។ កុំអោយច្រឡំថា កូនតូចមិនអាចទទួលសេចក្តីសង្គ្រោះបាននោះឡើយ។ នៅក្នុងម៉ាកុស ១០:១៣-១៦ ព្រះយេស៊ូមានព្រះបន្ទូលថា "ទុកអោយកូនក្មេងមកឯខ្ញុំចុះ" ។ បើសិនជាកូនអ្នកមានជំនឿលើព្រះយេស៊ូ ហើយទទួលស្គាល់ថា ខ្លួនជាមនុស្សអាក្រក់ គេអាចទទួលសេចក្តីសង្គ្រោះបាន ។

២. ឪពុកម្តាយត្រូវធ្វើគំរូជាមនុស្សដែលស្រលាញ់ព្រះអង្គអស់ពីចិត្ត កូនយើងអាចឃើញច្បាស់ បើសិនឪពុកម្តាយស្រលាញ់ទ្រព្យសម្បត្តិ មុខមាត់ និងផ្ទះសំបែងជាជាងស្រលាញ់ព្រះអង្គ ។ បើព្រះជារតនៈសម្បត្តិចំពោះឪពុកម្តាយ កូនក៏ចង់បានរតនៈសម្បត្តិនោះដោយអស់ពីចិត្តដែរ ។

៣. ឪពុកម្តាយត្រូវអោយកូនឃើញថា ឪពុកម្តាយសប្បាយចិត្តនឹងលះបង់អ្វីៗទាំងអស់ សំរាប់ព្រះជាម្ចាស់ ។

## គ. ឪពុកម្តាយត្រូវបង្រៀនកូនអោយស្តាប់បង្គាប់ព្រះជាម្ចាស់

កូនរៀនពីការស្តាប់បង្គាប់ព្រះ តាមការស្តាប់បង្គាប់ឪពុកម្តាយ ។ កូនរបស់អ្នកស្តាប់អ្នក យ៉ាងណា គេក៏ស្តាប់ព្រះជាម្ចាស់យ៉ាងនោះដែរ។ បើគេមិនព្រមស្តាប់ឪពុកម្តាយទេ គេក៏មិនព្រមស្តាប់ព្រះដែរ។

១. ឪពុកម្តាយត្រូវតែបង្រៀនកូនអោយបានច្បាស់លាស់ អំពីក្រឹតវិន័យរបស់ព្រះអង្គ

- ឪពុកម្តាយត្រូវបង្រៀនកូនអំពីក្រឹត្យវិន័យ១០ប្រការ នៅក្នុង និក្ខមនំ ២០
- ឪពុកម្តាយត្រូវបង្រៀនកូនអំពីច្បាប់របស់ព្រះមហាក្សត្រយេស៊ូ នៅក្នុង ម៉ាថាយ ៥,៦,៧
- ឪពុកម្តាយត្រូវបង្រៀនកូនអំពីភារកិច្ចរបស់ក្រុមជុំនំ នៅក្នុង រ៉ូម ១២
- ឪពុកម្តាយត្រូវបង្រៀនកូនអំពីប្រាជ្ញារបស់ព្រះអង្គ នៅក្នុង សុភាសិត

២. ឪពុកម្តាយត្រូវពន្យល់អំពីច្បាប់នៅក្នុងគ្រួសារអោយបានច្បាស់លាស់

៣. ឪពុកម្តាយត្រូវបង្រៀនកូនអោយស្តាប់បង្គាប់ ដោយអស់ពីចិត្ត

ការស្តាប់បង្គាប់អស់ពីចិត្តមានលក្ខណៈ៣យ៉ាង ៖

- **ស្តាប់ភ្លាម** ដូច្នេះ ការពន្យាពេលស្តាប់នោះ ឪពុកម្តាយត្រូវរាប់ថាជាការមិនស្តាប់វិញ
- **ស្តាប់ដោយចិត្តសុភាព** ដូច្នេះ ការស្តាប់ដោយចិត្តខឹងនោះ ឪពុកម្តាយត្រូវរាប់ថាជាការមិនស្តាប់វិញ
- **ស្តាប់ទាំងស្រុង** ដូច្នេះ ការស្តាប់តែខ្លះៗប៉ុណ្ណោះនោះ ឪពុកម្តាយត្រូវរាប់ថាជាការមិនស្តាបវិញ

កូនជាច្រើនមិនស្តាប់ឪពុកម្តាយភ្លាមទេ ។ ទាល់តែឪពុកម្តាយបង្គាប់៤ឬ៥ដង ហើយតម្លើងសម្លេងទៀត ទើបគេព្រមធ្វើតាម ពេលឪពុកម្តាយបង្គាប់ច្រើនដងដូច្នោះ កូនយល់ថា "ខ្ញុំមិនបាច់ធ្វើតាមឪពុកម្តាយភ្លាមទេ! ខ្ញុំអាចពន្យាពេលស្តាប់រហូតដល់លើកទី៤ លើទី៥!" តាមពិតឪពុកម្តាយដែលធ្វើរបៀបនោះ បានបង្រៀនកូនពីការ មិនបាច់ស្តាប់ឪពុកម្តាយ ច្រើនជាងការដែលគេត្រូវស្តាប់ឪពុកម្តាយ !

## ឃ. ឪពុកម្តាយត្រូវបង្រៀនកូនអោយបំរើព្រះជាម្ចាស់

គោលដៅរបស់ឪពុកម្តាយ គឺអោយកូនក្លាយទៅជាអ្នកបំរើព្រះ និងអ្នកឯទៀត។ សូមអាន ម៉ាថាយ ២០:២៨, កាឡាទី ៥:១៣ និង ម៉ាថាយ ៤:១០ បើកូនឃើញឪពុកម្តាយបំរើព្រះ និងអ្នកឯទៀត ដោយចិត្តរីករាយ នោះគេក៏នឹងមានចិត្តចង់បំរើព្រះអង យ៉ាងដូច្នោះដែរ។ ឧទាហរណ៍: ពេលណាអ្នកទៅសួរសុខទុកក្រុមជុំនំម្នាក់ នៅឯមន្ទីរពេទ្យ សូមយកកូនទៅជាមួយ ដើម្បីជួយអោយកូនរៀនពីការបំរើ ។

## ង. ឪពុកម្តាយត្រូវបង្រៀនកូនអោយជឿទុកចិត្តលើព្រះជាម្ចាស់

ជាការពិត កូនរបស់យើងនឹងរំលងក្រឹត្យវិន័យរបស់ព្រះ ច្រើនជាងធ្វើតាម។ ប៉ុន្តែមិនមែនតែពួកគេប៉ុណ្ណោះទេ យើងជាឪពុកម្តាយក៏មិនធ្វើតាមភារៈកិច្ចរបស់ខ្លួនជាច្រើនដងដែរ។ នេះជាមូលហេតុដែលមិនគ្រប់គ្រាន់សម្រាប់យើង ដោយគ្រាន់តែបង្រៀនច្បាប់ដល់គ្រួសាររបស់ខ្លួន សូម្បីតែជាច្បាប់ល្អក្តី។ ច្បាប់ល្អនឹងមិនដែលអាចសង្គ្រោះអ្នកណាបានឡើយ។ យើងត្រូវបង្រៀនដំណឹងល្អអំពីព្រះយេស៊ូវដល់គ្រួសាររបស់យើងជារៀងរាល់ថ្ងៃ! ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអាទិករដែលបានយាងមកផែនដី ដើម្បីសង្គ្រោះមនុស្សដូចជាយើង ដែលបានរំលងគ្រប់ទាំងច្បាប់វិន័យ។ ចូរបង្រៀនកូនរបស់អ្នកថា ព្រះគ្រីស្ទបានយាងមកដើម្បីសង្គ្រោះមនុស្សបាប មិនមែនសង្គ្រោះមនុស្សល្អទេ។ មានតែអ្នកមានបាបទេ ដែលអាចបានសង្គ្រោះ

ហើយនោះគឺជាដំណឹងល្អ ព្រោះយើងទាំងអស់គ្នាគឺជាអ្នកមានបាប។ អស់អ្នកណាដែលបះបោរប្រឆាំងនឹងក្រឹត្យវិន័យដ៏ល្អរបស់ព្រះ គឺសមនឹងស្លាប់ ហើយបែកចេញពីព្រះ ក៏ប៉ុន្តែព្រះយេស៊ូវគ្រីស្ទបានសុគតនៅលើឈើឆ្កាងជំនួយយើង ហើយទទួលរងទុក្ខដោយបែកចេញពីព្រះជាម្ចាស់ ដែលយើងសមនឹងទទួល។ បន្ទាប់មកទ្រង់បានរស់ពីសុគតឡើងវិញ ហើយចាត់ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ មកគង់នៅក្នុងអស់អ្នកណាដែលជឿលើព្រះយេស៊ូវគ្រីស្ទ។ ដោយព្រះវិញ្ញាណបរិសុទ្ធរស់នៅក្នុងយើង នោះយើងអាចមានព្រះចេស្ដា ក្នុងការធ្វើតាមក្រឹត្យវិន័យដ៏ល្អរបស់ព្រះជាម្ចាស់។

មេរៀនទី ៣

# របៀបបង្រៀនកូនអោយចេះស្តាប់បង្គាប់បភ្លាមពេលប្រាប់លើកទីមួយ

## ក. ឪពុកម្តាយត្រូវតែងច្បាប់ទំលាប់ក្នុងគ្រួសារយ៉ាងច្បាស់លាស់

១. ឪពុកម្តាយត្រូវតែមានចិត្តតែមួយអំពីច្បាប់ទំលាប់ទាំងអស់នេះសិន បើឪពុកម្តាយគ្មាន ចិត្តតែមួយអំពីច្បាប់ទំលាប់ទាំងអស់នេះទេនោះ កូនក៏មិនស្តាប់ដែរ ។

២. ឪពុកម្តាយត្រូវហៅកូនទាំងអស់មកស្តាប់ច្បាប់ទំលាប់នៅក្នុងគ្រួសារ ។ ប្រាប់គេថា “កូនជារបស់ផងព្រះអង្គ ព្រះអង្គបានប្រទានកូនមកអោយប៉ាម៉ាក់ក្នុងរយះពេលខ្លី ។ ថ្ងៃណា មួយប៉ាម៉ាក់នឹងត្រូវប្រឈមមុខជាមួយព្រះអង្គ ដើម្បីអោយទ្រង់វិនិច្ឆ័យប៉ាម៉ាក់ អំពីការអប់រំកូន ។ នៅក្នុងគ្រួសារនេះ យើងទាំងអស់គ្នាត្រូវតែធ្វើតាមបញ្ញត្តិរបស់ព្រះ បើកូនមិនធ្វើតាម ប៉ាម៉ាក់ត្រូវជួយកូនអោយធ្វើតាម បើប៉ាម៉ាក់ធ្វេស ប្រហែសមិនកែកូន នោះនឹងនាំកូនអោយបែរចេញពីព្រះអង្គ ហើយទទួលសេចក្តីស្លាប់ យើងតែងច្បាប់ទាំងនេះ ព្រោះយើងស្រលាញ់កូនខ្លាំងណាស់”

៣. បង្រៀនច្បាប់អោយកូន ប្រើក្រដាស់មេរៀន “នៅក្រុមគ្រួសារនេះ យើងស្រលាញ់ព្រះ..”

៤. កំហុសណាដែលនាំអោយកូនស្លាប់ ហើយបែចេញពីព្រះអង្គ ឪពុកម្តាយត្រូវតែប្រើរំពាត់ ក្នុងការប្រៀនប្រដៅ ។ ជាពិសេស ការកុហក់ ការមិនស្តាប់បង្គាប់ច្បាប់របស់ឪពុកម្តាយ ការវាយតប់ជាមួយអ្នកដ៏ទៃ ការសងសឹក ការលួច ការជេរ ការបំផ្លាញរបស់របរ ជាដើម។ កូនត្រូវស្តាប់បង្គាប់ឪពុកម្តាយភ្លាម ដោយចិត្តសុភាព ហើយទាំងស្រុង ។

៥. បើឪពុកម្ដាយមិនបានបង្រៀនច្បាប់យ៉ាងច្បាស់លាស់ គាត់អត់មានសិទ្ធិវាយប្រដៅទេ ។

## ខ. កុំអោយឪពុកម្ដាយប្រើកំហឹងក្នុងការអប់រំឡើយ

កំហឹងឪពុកម្ដាយមិនដែលជួយឡើយ ផ្ទុយទៅវិញ កំហឹងនោះនាំអោយកូនលែងគោរពឪពុក ម្ដាយ ។ អាន យ៉ាកុប ១:១៩-២០ ឪពុកម្ដាយមិនបាច់ប្រើកំហឹងទេ ព្រោះឪពុកម្ដាយមាន អំណាចលើកូនរបស់គេហើយ ឧទាហរណ៍ ប៉ូលិសដែលផាកម៉ូតូ មិនបាច់ប្រើកំហឹងទេ តែយើងចេះតែធ្វើតាម។ ប៉ូលិសដឹងថាគេមានអំណាច លើយើងហើយ បានជាគេមិនបាច់ប្រើកំហឹង ។ ដូចគ្នាដែរ ឪពុកម្ដាយមានអំណាច ពីព្រះអង្គ មិនបាច់ប្រើកំហឹងទេ ។

## គ. ឪពុកម្ដាយត្រូវមានចិត្តគំនិតតែមួយអំពីការប្រើរំពាត់

ឪពុកម្ដាយប្រើរំពាត់ ពីព្រោះគាត់ស្រលាញ់កូន និងស្រលាញ់ព្រះអង្គ ។ សុភាសិត ១៣:២៤ "អ្នកណាដែលមិនសូវប្រើរំពាត់ នោះឈ្មោះថាស្អប់កូន តែអ្នកណាដែលស្រលាញ់កូនវិញ ឧស្សាហ៍វាយផ្ចាលវា " បើឪពុកម្ដាយប្រើរំពាត់តាមរបៀបត្រឹមត្រូវ នោះកូននឹងយល់ច្បាស់ថា ឪពុកម្ដាយស្រលាញ់គេ ។ អាន វិវរណៈ ៣:១៩; សុភាសិត ៣:១២; ១៩:១៨; ២៣:១៣–១៤; ២៥:១៥ ។

## ឃ. ឪពុកម្ដាយត្រូវប្រើរំពាត់តាមរបៀបត្រឹមត្រូវ

១. អ្នកត្រូវសួរខ្លួនឯងថា តើខ្លួនខឹងឬអត់? បើខឹងចាំសិន កុំអាលប្រៀនប្រដៅកូន

២. អ្នកត្រូវសួរខ្លួនឯងថា តើខ្ញុំបានបង្រៀនពីច្បាប់ក្នុងគ្រួសារយ៉ាងច្បាស់លាស់ ហើយឬនៅ?

បើកូនមិនទាន់ច្បាស់ពីច្បាប់នៅក្នុងគ្រួសារទេ អ្នកត្រូវពន្យល់ថែមទៀត មិនមែនប្រើរំពាត់ទេ។

៣. អ្នកត្រូវនាំកូនទៅកន្លែងស្ងាត់ កុំឲ្យប្រើរំពាតនៅមុខគេ។

៤. អ្នកត្រូវសួរកូនពីការដែលកូនបានធ្វើខុស បើកូនថាមិនដឹង ចូរប្រាប់គាត់ឲ្យដឹង។

៥. អ្នកត្រូវឲ្យកូនទទួលស្គាល់ពីការដែលគាត់បានធ្វើខុស។

៦. អ្នកត្រូវរំលឹកកូនថា ប៉ាមិនមែនវាយកូនដោយសារប៉ាខឹងទេ តែប៉ាវាយកូនដើម្បីរំដោះកូន ចេញពីចិត្តអាក្រក់ ដែលនាំឲ្យកូនស្លាប់ ហើយដើម្បីនាំកូនមកឯព្រះវិញ សុភាសិត ២២:១៥

៧. អ្នកត្រូវប្រាប់កូនពីចំនួនរំពាត់ ដែលត្រូវវាយ។ (បើប្រាប់ចំនួនមុន កូននឹងដឹងថា ឪពុកមិនមែនវាយកូនដោយកំហឹង រហូតដល់បាត់ខឹងទេ គឺមានកំរិត)។

៨. អ្នកត្រូវជ្រើសរើសរំពាត់សមល្មម ដែលធ្វើអោយឈឺ តែមិនធ្វើអោយមានរបួស ឬជាំ។

៩. អ្នកត្រូវផ្តេកកូននៅលើភ្លៅទាំងពីររបស់អ្នក ឬអោយទយគូថ ហើយវាយត្រង់កំប៉េះគូថ កុំវាយស្រាលពេក កុំវាយខ្លាំងពេកនាំឲ្យមានរបួស តែត្រូវវាយឲ្យកូនដឹងឈឺ។ (បើគេស្លៀកខោក្រាស់ ត្រូវទាញចុះ)។

១០. បើកូនរើបម្រាស់មិនព្រមទទួលពិន័យទេ អ្នកត្រូវប្រាប់គេថា បើមិននៅស្ងៀមទេ ប៉ាត្រូវ តែថែមមួយរំពាត់ទៀត។

១១. បើកូនអត់យំ មានន័យថាអ្នកបានវាយស្រាលដៃពេក ហើយបើកូនស្រែកខ្លាំងបែកផ្ទះ ក៏មានន័យថា អ្នកបានវាយស្រាលដៃពេកដែរ ហើយវាគ្រាន់តែខឹងអ្នកតែប៉ុណ្ណោះ។ អ្នកអាចយល់ចិត្តគេថា តើគេមានចិត្តទន់ហើយឬនៅ។ បើកូននៅតែខឹង អ្នកត្រូវប្រើរំពាត់ទៀត។

១២. ក្រោយពេលវាយកូនរួច នៅពេលដែលកូនឈប់យំក្លាង អ្នកត្រូវអោបកូន ហើយប្រាប់គេថា ប៉ាស្រឡាញ់កូនណាស់។

១៣. អ្នកត្រូវអធិស្ឋានជាមួយកូន នាំកូនអោយសារភាពបាបចំពោះព្រះ ហើយចំពោះអ្នកផ្សេងទៀតដែលកូនបានធ្វើខុសជាមួយ។

១៤. កុំរំលឹកកូន អំពីកំហុសដែលកូនបានធ្វើនេះទៀត។ អាន សុភាសិត ២៣:១៣; ២៩:១៥-១៧; ១៣:២៤; ហេព្រើរ ១២:៥-១២

# នេះជារបៀបដែលយើងអធិស្ឋានប្រចាំអាទិត្យសម្រាប់កូនចៅរបស់យើង

ដោយចេឌី និង ឃីម

អស់រយៈពេលជាង៣០ឆ្នាំ ឃីម និង ខ្ញុំបានអធិស្ឋានសម្រាប់កូន ចៅ ចៅទួត និង ប្ដីប្រពន្ធរបស់ពួកគេ (ជាធម្មតា គឺធ្វើពេលអធិស្ឋានតមអាហារថ្ងៃត្រង់នៅថ្ងៃអង្គារ ឬ ថ្ងៃពុធ)។ ព្រមទាំងអធិស្ឋានសម្រាប់សំណូមពរពិសេសរបស់គេម្នាក់ៗ តាម សេចក្ដីត្រូវការ យើងក៏បានអធិស្ឋានសំណូមពរទូទៅខាងក្រោមនេះជានិច្ច រាល់ អាទិត្យ រាល់ខែ រាល់ឆ្នាំ។ ហើយយើងមានចិត្តអស្ចារ្យ ពីការឆ្លើយតបដ៏ស្មោះត្រង់ ពីព្រះជាម្ចាស់។ យើងអធិស្ឋានកាន់តែច្រើន យើងក៏បានទទួលកាន់តែច្រើនដែរ។ ព្រះបានប្រទានឲ្យយើងពីរនាក់មានជំនឿល្មម ដើម្បីជឿថាព្រះអង្គនឹងឆ្លើយតប សំណូមទាំងនេះដល់ជំនាន់ទីបួន គឺដល់ជំនាន់ចៅទួតរបស់យើង។ ហើយហួសពី នោះ គឺជាភារកិច្ចរបស់កូនយើងដែលត្រូវបន្តអធិស្ឋានសម្រាប់កូនចៅរបស់ ពួកគេទៀត។

**ជំនឿ**

- សូមឲ្យពួកគេកែប្រែចិត្តពីអំពើបាប
- សូមប្រទានឲ្យពួកគេមានជឿលើព្រះយេស៊ូវគ្រីស្ទ តាំងពីនៅក្មេង
- សូមបំពេញពួកគេដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ និង ផលផ្លែនៃព្រះវិញ្ញាណ
- សូមនាំពួកគេឲ្យជ្រមុជទឹកចូលក្នុងក្រុមជំនុំរបស់ទ្រង់
- សូមឲ្យពួកគេធ្វើជាសមាជិកនៃក្រុមជំនុំរឹងមាំ ដោយមានអ្នកដឹកនាំដែលកោតខ្លាច ព្រះ
- សូមប្រទានអំណោយទានខាងវិញ្ញាណដល់ពួកគេ ហើយជួយពួកគេឲ្យប្រើ អំណោយទានទាំងនោះដោយស្មោះត្រង់
- សូមជួយឲ្យពួកគេរីកចំរើនក្នុងភាពបរិសុទ្ធ
- សូមរក្សាពួកគេក្នុងសេចក្ដីជំនឿត្រឹមត្រូវរបស់ព្រះគ្រីស្ទ និងពួកសាវក

- សូមការពារពួកគេពីគ្រូខុសឆ្គង និង សេចក្តីបង្រៀនខុសឆ្គង
- សូមឲ្យពួកគេប្រកាសដំណឹងល្អ ដែលពេញដោយផលផ្លែ ហើយពេញដោយសេចក្តីស្រឡាញ់ចំពោះមនុស្សទាំងអស់
- សូមឲ្យពួកគេផ្តាជ្ញាចិត្តក្នុងការអធិស្ឋានប្រចាំថ្ងៃ ដោយចិត្តសុភាព
- សូមឲ្យពួកគេស្រេកឃ្លានក្នុងការអានព្រះបន្ទូលប្រចាំថ្ងៃ
- សូមបំពេញពួកគេដោយសេចក្តីស្រឡាញ់ និងចិត្តអត់ធ្មត់ចំពោះអ្នកដទៃ
- សូមជួយពួកគេឲ្យចេះស៊ូទ្រាំចំពោះការលំបាក ដោយសេចក្តីជំនឿ និង ដោយអំណរ
- សូមជួយពួកគេឲ្យចេះការពារមនសិការរបស់ខ្លួន
- សូមឲ្យជីវិតរបស់ពួកគេ បានដូចជាព្រះអាទិត្យដែលរះកាន់តែខ្លាំងទៅៗ រហូតដល់ថ្ងៃត្រង់

## ប្រាជ្ញា

- សូមប្រទានឲ្យពួកគេមានចិត្តដែលហូរហៀរដោយការអរគុណ
- សូមធ្វើឲ្យពួកគេជាអ្នកដែលបង្កើតសុខសន្តិភាព
- សូមឲ្យពួកគេមានមុខជំនាញ ដែលអាចចិញ្ចឹមគ្រួសារ និង មានប្រយោជន៍ដល់សង្គម
- សូមជួយឲ្យពួកគេស្គាល់គោលបំណងរបស់ព្រះអង្គចំពោះការងារប្រចាំជីវិត ហើយធ្វើដោយអំណរ
- សូមការពារពួកគេពីការខ្លាចចិត្តមនុស្ស
- សូមផ្តល់ការអប់រំល្អដល់ពួកគេ
- សូមជួយឲ្យពួកគេយកចិត្តទុកដាក់ក្នុងការរៀនសូត្រ និង ការងារទាំងឡាយដែលគេធ្វើ
- សូមរំដោះពួកគេឲ្យចេញពីភាពខ្ជិលច្រអូស និង ភាពមិនស្មោះត្រង់។

## ឥទ្ធិពល និង ទំនាក់ទំនង

- សូមឲ្យពួកគេមានចិត្តឆាប់អត់ទោស
- សូមឲ្យពួកគេមានមិត្តភក្តិល្អៗ អស់មួយជីវិតគេ ដែលជួយឲ្យពួកគេស្រឡាញ់ព្រះ
- សូមឲ្យពួកគេមានឥទ្ធិពលល្អពី “ពូ មីង អ៊ំ និង ឪពុកម្តាយ ក្នុងព្រះ” ជាពិសេស នៅពេលពួកគេចាកចេញពីផ្ទះ
- សូមកុំបណ្តោយឲ្យពួកគេភ្លឹតភ្លឹននៅក្នុងយុវវ័យរបស់ពួកគេឡើយ
- សូមជួយឲ្យពួកគេថែរក្សាភាពបរិសុទ្ធ ហើយដល់ថ្ងៃរៀបការជាមនុស្សបរិសុទ្ធ
- សូមឲ្យពួកគេរៀបការជាមួយតែអ្នកដែលមានជំនឿមាំ
- សូមសង្គ្រោះ និងប្រទានពរដល់អ្នកដែលត្រូវធ្វើជាគ្រួសារអនាគតរបស់ពួកគេ
- សូមរក្សាពួកគេកុំអោយមានការលែងលះក្នុងជីវិតរបស់ពួកគេ ហើយនិងក្នុងជីវិតកូនចៅរបស់ពួកគេជាច្រើនតំណ
- សូមប្រទានពរឲ្យពួកគេមានកូនចៅ ហើយទទួលព្រះគុណ ដើម្បីបង្រៀនកូនចៅទាំងនោះ ក្នុងសេចក្តីជំនឿនៃព្រះយេស៊ូវគ្រីស្ទ
- បើពួកគេអត់យកប្តីប្រពន្ធ សូមធ្វើឲ្យពួកគេមានផលផ្លែយ៉ាងច្រើនក្នុងរាជរបស់ព្រះវិញ
- សូមការពារពួកគេពីមនុស្សដែលចង់ធ្វើបាបពួកគេ ខាងការរួមភេទ
- សូមការពារពួកគេពីការស្រឡាញ់ភេទដូចគ្នា និងការខុសឆ្គងផ្សេងៗទៀត

## សាច់ឈាម

- សូមប្រោស និងការពារពួកគេពីជំងឺ និង មេរោគផ្សេងៗ
- សូមការពារពួកគេពីគ្រោះថ្នាក់
- សូមឲ្យប្រទេសដែលពួកគេរស់នៅមានសុខសន្តិភាព ៚